# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1205

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : គម្រោងលើកកម្ពស់ការអប់រំបរិស្ថាននិងការប្រតិបត្តិបរិស្ថានដ៏ប្រសើរ

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/26

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/28

៣. ចំណាយគម្រោងសរុប $154,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងបរិស្ថាន

RESPONSIBLE UNIT Department of Environmental Education/ General Directorate of Environmental Knowledge and Information

អង្គភាពទទួលខុសត្រូវ នាយកដ្ឋានអប់រំបរិស្ថាន/អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទានៈ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៥- ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះនឹងចូលរួមចំណែកច្រើន ដើម្បីសម្រេចបាននូវគោលនយោបាយជាតិ និងយុទ្ធសាស្ត្របច្ចកោណ ដោយប្រែក្លាយចំណេះដឹងបរិស្ថានឱ្យទៅជាការអនុវត្ត ដូចនេះប្រជាជនកម្ពុជានឹងមានឥរិយាបថវិជ្ជមានចំពោះបរិស្ថាន និងសម្រេចបានការអភិវឌ្ឍដោយចីរភាព។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៏វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១.វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កោះកុង, កែប, កំពត, ព្រះសីហនុ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងនេះមានគោលបំណងលើកកម្ពស់អំពីសារៈប្រយោជន៍របស់បរិស្ថាន និងបញ្ហាប្រែប្រួលអាកាសធាតុ ដល់សាធារណជន ដូចនេះពួកគាត់ក្លាយជាធនធានមនុស្សបរិស្ថាន។ ការអប់រំបរិស្ថានគឺជាមធ្យោបាយមួយ ដើម្បី សម្រេចបាននូវការអភិវឌ្ឍដោយចីរភាព។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គោលបំណងមូលដ្ឋាននៃការអប់រំបរិស្ថានគឺការធ្វើឱ្យបុគ្គល និងសហគមន៍យល់អំពីភាពស្មុគស្មាញនៃធម្មជាតិ និងបរិស្ថាន និងផ្តល់ចំណេះដឹង តម្លៃ ឥរិយាបថ និងជំនាញអនុវត្តន៍ដែលអាចឱ្យពួកគាត់ឆ្លើយតបនឹងបញ្ហាបរិស្ថានប្រកបដោយប្រសិទ្ធភាព។ ដើម្បីអនុវត្តន៍គម្រោងនេះទទួលបានជោគជ័យ ផ្នែកចំនួនបួនត្រូវតែអនុវត្តន៍៖

១. មធ្យោបាយចល័ត៖ គម្រោងត្រូវការរថយន្តយ៉ាងតិច១គ្រឿង ដើម្បីធ្វើដំណើរ និងបំពាក់សម្ភារឧបទេសអប់រំបរិស្ថាន។

២. ឧបករណ៍ចាក់បញ្ចាំង និងសំឡេង៖ គម្រោងត្រូវការទូរទស្សន៍យ៉ាងតិចមួយគ្រឿង ឧបករណ៍បំពងសំឡេងយ៉ាងតិចមួយឈុត និងឧបករណ៍ស្តុកថាមពលអគ្គិសនី ដើម្បីចាក់បង្ហាញអំពីវីដេអូអប់រំបរិស្ថាននានា។

៣. សម្ភារឧបទេសអប់រំបរិស្ថាន៖ គម្រោងនឹងរៀបចំផលិតប័ណ្ណផ្សព្វផ្សាយ ផ្ទាំងមេរៀន និងសៀវភៅមេរៀន បរិស្ថាននានា ដើម្បីចែកជូនដល់សាធារណជន និងសិស្ស។

៤. សកម្មភាពអប់រំបរិស្ថាន៖ ក្រុមការងារអប់រំបរិស្ថាន នឹងចុះទៅតាមសហគមន៍ និងទីសាធារណនានា ដើម្បីអប់រំ និងផ្សព្វផ្សាយអំពីចំណេះដឹងបរិស្ថាន។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

សង្គមរបស់យើងត្រូវការធនធានមនុស្សបរិស្ថាន ឬ មនុស្សដែលស្រឡាញ់បរិស្ថាន ឬមនុស្សដែលមានឥរិយាបថវិជ្ជមានចំពោះបរិស្ថាន ដើម្បីសម្រេចបាននូវការចីរភាពបរិស្ថាន ហើយគម្រោងនេះផ្តោតសំខាន់លើការអប់រំបរិស្ថាន និងផ្លាស់ប្តូរឥរិយាបថប្រជាពលរដ្ឋឱ្យស្រឡាញ់បរិស្ថាន និងធម្មជាតិ។ ដូចនេះហើយ គម្រោងនេះគួរត្រូវបានគាំទ្រ ទាំងថវិកា និងបច្ចេកទេស។ ជាមួយគ្នានេះផងដែរ គម្រោងនេះនឹងចូលរួមចំណែកយ៉ាងច្រើន ដើម្បីសម្រេចបាន ផែនការយុទ្ធសាស្រ្ត និងយុទ្ធសាស្រ្តចតុកោណជំណាក់កាលទី៤។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់សាធារណជនដែលបានទទួលពីក្រុមការងារអប់រំបរិស្ថាន ហើយពួកគាត់នឹងអប់រំបន្តដល់អ្នកដែលនៅជុំវិញខ្លួន។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | គ្មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទានចាប់ផ្តើម |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះមិនមានផលប៉ះពាល់អវិជ្ជមានដល់មនុស្ស និងបរិស្ថាននោះទេ ប៉ុន្តែវាផ្តល់នូវផលវិជ្ជមានជាច្រើន ដល់សង្គមមនុស្ស និងបរិស្ថាន។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ទាំងពីរ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| **១១. ជីវៈចម្រុះនិងការអភិរក្ស** | 80 | **ទាក់ទងខ្លាំង** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះនឹងអនុញ្ញាតឱ្យមានចូលរួមស្មើភាពគ្នារវាងបុរស និងស្ត្រី។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងបរិស្ថានមានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ ដើម្បីអនុវត្តន៍គម្រោងនេះ ប៉ុន្តែដើម្បីឱ្យការអនុវត្តកាន់តែរលូន គម្រោងនេះអាចត្រូវការទីប្រឹក្សាបច្ចេកទេស ដើម្បីជួយចង្អុលបង្ហាញផងដែរ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការពន្យាពេលក្នុងការអនុវត្តគម្រោង។)

**នេះជាគម្រោងថ្មី និងកំពុងស្វែងរកជំនួយគាំទ្រ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

10

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**នេះជាគម្រោងថ្មី និងមិនទាន់មានដៃគូគាំទ្រនៅឡើយទេ។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 12.0 | 12.0 | 12.0 | 36.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 12.0 | 12.0 | 12.0 | 36.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 106.0 | 6.0 | 6.0 | 118.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 6.0 | 6.0 | 6.0 | 18.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 100.0 | 0.0 | 0.0 | 100.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 118.0 | 18.0 | 18.0 | 154.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 118.0 | 18.0 | 18.0 | 154.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: